**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០០៧/០២/២០០៨ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ២០០៨

**ជម្រាបមក**

**- លោកប្រធានគណបក្សសង្គមយុត្តិធម៌**

**- លោកប្រធានគណបក្សខ្មែរឈប់ក្រ**

**កម្មវត្ថុ** : រឿងទាក់ទងនឹងការប្ដឹងគ.ជ.ប. និង UNDP ពីបទមិនគោរពច្បាប់បោះឆ្នោត

**យោង** : បណ្ដឹងគ្មានលេខ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ២០០៨ របស់ប្រធានគណបក្សសង្គមយុត្តិធម៌ និងប្រធានគណបក្សខ្មែរឈប់ក្រ

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបលោកប្រធានទាំងពីរថា ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ២០០៨ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យលើបណ្ដឹងរបស់លោករួចហើយ ។ ក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា ពុំអាចលើកយកបណ្ដឹងរបស់លោក មកពិភាក្សា និង សម្រេចបានឡើយ ពីព្រោះបណ្ដឹងនេះមិនចូលក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានចែងក្នុង មាត្រា ២៥ ថ្មី មាត្រា ២៦ និង មាត្រា ២៧ ថ្មី នៃច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ និង មាត្រា ៧៣ ថ្មី នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នោះទេ ។

សូមលោកប្រធានគណបក្សទាំងពីរ ទទួលនូវការរាប់អានអំពីខ្ញុំ ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**